ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
Ministry of Environment

លេខ: ៣៦១ ប្រក ........ប.ស្ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ២០០៩

# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៨ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

លេខ ៤៨ វិថីព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ : (ស្តង់ដា) ០២៣ ២១ ៣៤ ៦២ / ០២៣ ២១ ២៩ ៥៤
ទូរសារ : ៨៥៥ ២៣ ២១ ២៥

20.08.12

- បានឃើញប្រកាសរួមលេខ ២៤៥ សហវ.បស្ត.ប្រក ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០០ ស្តីពីការកំណត់ថ្លៃសេវាការងារសំរាប់ការពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន និងការតាមដាន ឃ្លាំមើលការអនុវត្តន៍គំរោងរវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ២៣០ ប្រក.បស្ត ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពីប្រតិភូកម្មអំណាចក្នុងការធ្វើសេចក្តីសំរេចក្នុងនាមក្រសួង ចំពោះគំរោងវិនិយោគ ជូនមន្ទីរបរិស្ថានខេត្ត-ក្រុង
- បានឃើញប្រកាសលេខ ៣៤៦ ប្រក.សសរ.បស្ត ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## **សំរេច**

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងអនុវត្តគោលការណ៍ណែនាំទូទៅស្តីពីការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពេញលេញ និងតារាងសង្ខេប ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និង ២ នៃប្រកាសនេះ ។

**ប្រការ២.-**

ម្ចាស់គំរោងជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋ ជាក្រសួង/ស្ថាប័នរដ្ឋ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លើគំរោងស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពី "កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន" ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសំរេចដោយរាជរដ្ឋាភិបាល ។

**ប្រការ៣.-**

ម្ចាស់គំរោងដូចមានចែងនៅក្នុងប្រការ ២ ខាងលើ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ លើគំរោងដែលបានស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសលេខ ២៣០ ប្រក.បស្ត ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០៥ ស្តីពី "ប្រតិភូកម្មអំណាច ក្នុងការធ្វើសេចក្តីសំរេចក្នុងនាមក្រសួង ចំពោះគំរោងវិនិយោគជូនមន្ទីរបរិស្ថានខេត្ត-ក្រុង" ដើម្បីដាក់ជូនមន្ទីរបរិស្ថានរាជធានី-ខេត្តពិនិត្យ និងផ្តល់យោបល់ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសំរេចដោយរាជរដ្ឋាភិបាល ។

### ប្រការ៤.-

ម្ចាស់គំរោងដូចមានចែងនៅក្នុងប្រការ ២ និង ៣ ខាងលើ អាចប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនទីប្រឹក្សា ដែលជាអ្នកទទួលខុសត្រូវផ្ទាល់ក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញ ដោយគោរពទៅតាមគោលការណ៍ណែនាំទូទៅនេះ។

### ប្រការ៥.-

ករណីម្ចាស់គំរោងអាចសរសេររបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញ ដោយខ្លួនឯងផ្ទាល់ នោះក្រុមសរសេររបាយការណ៍ត្រូវតែមានសមត្ថភាពជំនាញគ្រប់គ្រាន់ ក្នុងការរៀបចំរបាយការណ៍ ដោយមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

### ប្រការ៦.-

ក្រុមហ៊ុនទីប្រឹក្សាដូចមានចែងនៅក្នុងប្រការ ៤ ត្រូវមានលក្ខណៈសម្បត្តិ-សមត្ថភាពជំនាញគ្រប់គ្រាន់ក្នុងការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ មានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម និងមានការទទួលស្គាល់ពីក្រសួងបរិស្ថាន។

### ប្រការ៧.-

នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬ មន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវពិនិត្យ និងផ្តល់យោបល់លើទីតាំងគំរោង ដូចមានចែងនៅក្នុងប្រការ២ និង៣ខាងលើ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ថា គំរោងនេះគួរតំរូវឱ្យរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ។

### ប្រការ៨.-

ម្ចាស់គំរោងដូចមានចែងនៅក្នុងប្រការ២ និង៣ ត្រូវដាក់ពាក្យសុំពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ មកក្រសួងបរិស្ថាន ឬ មន្ទីរបរិស្ថានរាជធានី-ខេត្ត ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធមួយចំនួនដូចខាងក្រោម:

**ក-គំរោងសាធារណ:**

១. របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញជាភាសាខ្មែរ និងអង់គ្លេស

២. បង់ថ្លៃសេវាការងារដូចមានចែងនៅក្នុងប្រកាសរួមរវាងក្រសួងបរិស្ថាន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣. សៀវភៅគំរោងសិក្សាបុរេលទ្ធភាព/សមិទ្ធិលទ្ធភាព ចំនួន ០៣ ច្បាប់

៤. ផែនទី ប្លង់ទីតាំង និងប្លង់សាងសង់ជាផ្លូវការ ចំនួន ០៣ ច្បាប់

៥. ឯកសារពាក់ព័ន្ធនានា។

ខ-គំរោងឯកជន

១. របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញជាភាសាខ្មែរ និងអង់គ្លេស

២. បង់ថ្លៃសេវាការងារដូចមានចែងនៅក្នុងប្រកាសរួមរវាងក្រសួងបរិស្ថាន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៣. សៀវភៅគំរោងសិក្សាបុរេលទ្ធភាព/សមិទ្ធិលទ្ធភាព ចំនួន ០៣ ច្បាប់

៤. លក្ខន្តិកៈរបស់ក្រុមហ៊ុន ចំនួន ០៣ ច្បាប់

៥. វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម ចំនួន ០៣ ច្បាប់

៦. វិញ្ញាបនប័ត្រចុះបញ្ជីមានលក្ខខណ្ឌ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា ឬអនុគណៈកម្មាធិការវិនិយោគរាជធានី-ខេត្ត ចំនួន ០៣ ច្បាប់

៧. លិខិតអនុញ្ញាតពីអាជ្ញាធរដែនដី (បើសិនមាន) ចំនួន ០៣ ច្បាប់

៨. ផែនទី ប្លង់ទីតាំង និងប្លង់សាងសង់ជាផ្លូវការ ចំនួន ០៣ ច្បាប់

៩. ប័ណ្ណកម្មសិទ្ធិ ឬកិច្ចសន្យាជួលទីតាំង ចំនួន ០៣ ច្បាប់

១០. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែន (ថតចម្លង) របស់ប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ឬនាយកក្រុមហ៊ុនដែលជារូបវន្តបុគ្គល ចំនួន ០៣ ច្បាប់

១១. រូបថត ទំហំ ៤ X ៦ គ្រប់សមាជិកក្រុមប្រឹក្សាភិបាលដែលមាននៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ឬ នាយកក្រុមហ៊ុនដែលជារូបវន្តបុគ្គល ចំនួន ០៣ សន្លឹក

១២. ឯកសារពាក់ព័ន្ធនានា។

ម្ចាស់ក្រុមហ៊ុនត្រូវបញ្ជាក់ភាពស្របច្បាប់លើឯកសារថតចម្លង ចាប់ពីចំណុចទី៥ ដល់ចំណុចទី១០ នៃចំណុច (ខ) ពីសាលារាជធានី-ខេត្ត។

**ប្រការ៩.-**

នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញដោយអនុវត្តទៅតាមគោលការណ៍ណែនាំទូទៅនេះ។

**ប្រការ១០.-**

ក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញមានរយៈពេល៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តបានទទួលរបាយការណ៍ជាផ្លូវការ។ នីតិវិធីនេះត្រូវធ្វើឡើងជាបួនដំណាក់កាលសំរាប់ក្រសួង និងបីដំណាក់កាលសំរាប់រាជធានី-ខេត្ត។

**ប្រការ១១-**

ក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញរបស់ក្រសួងបរិស្ថាន ដោយគិតចាប់ពីថ្ងៃទទួលរបាយការណ៍ជាផ្លូវការមានដូចខាងក្រោម :

- មន្ត្រីជំនាញរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថានចុះពិនិត្យទីតាំងជាក់ស្តែង និងផ្តល់យោបល់ ក្នុងរយៈពេល ១០ថ្ងៃ
- អន្តរនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ថ្ងៃ
- ថ្នាក់ដឹកនាំរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ថ្ងៃ
- អន្តរក្រសួងមានរយៈពេល ០៥ថ្ងៃ ដែលមានការចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានានឹងគំរោងវិនិយោគ ដោយមានរដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាប្រធាន។

**ប្រការ១២-**

ក្នុងការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញរបស់មន្ទីរបរិស្ថានរាជធានី-ខេត្ត ដោយគិតចាប់ពីថ្ងៃទទួលរបាយការណ៍ជាផ្លូវការមានដូចខាងក្រោម:

- មន្ត្រីជំនាញរបស់មន្ទីរបរិស្ថានរាជធានី-ខេត្ត ចុះពិនិត្យទីតាំងជាក់ស្តែង និងផ្តល់យោបល់មានរយៈពេល ១៥ថ្ងៃ
- ថ្នាក់ដឹកនាំមន្ទីរបរិស្ថានរាជធានី-ខេត្ត មានរយៈពេល ០៥ថ្ងៃ
- អន្តរមន្ទីររាជធានី-ខេត្តមានរយៈពេល ០៥ថ្ងៃ ដែលមានការចូលរួមពីមន្ទីរ/អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានានឹងគំរោងវិនិយោគដោយមានប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត ជាប្រធាន។

**ប្រការ១៣-**

ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តមានរយៈពេល ០៥ថ្ងៃ ដើម្បីធ្វើលិខិតជាផ្លូវការតាមប្រការ១១ និង១២ខាងលើ ឯកភាពលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬ តំរូវឱ្យម្ចាស់គំរោងធ្វើការកែសម្រួលលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញឡើងវិញ។

ក្នុងករណី ក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តផ្តល់យោបល់ទៅម្ចាស់គំរោង ដើម្បីឱ្យកែសម្រួល នោះក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្តពិនិត្យ និងផ្តល់យោបល់ឡើងវិញក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីទទួលបានរបាយការណ៍កែសម្រួលខាងលើពីម្ចាស់គំរោង។

**ប្រការ១៤_**

នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត មានភារកិច្ចតាមដាន ឃ្លាំមើល និងចាត់វិធានការឱ្យម្ចាស់គំរោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថាន នៅក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងនៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដែលក្រសួងបរិស្ថាន ឬមន្ទីរបរិស្ថានរាជធានី-ខេត្ត បានឯកភាព។

**ប្រការ១៥_**

ម្ចាស់គំរោងត្រូវមានកាតព្វកិច្ចបង់មូលនិធិទាយជ្ជទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថានទៅតាមកិច្ចសន្យាការពារបរិស្ថានរបស់ក្រុមហ៊ុន។

**ប្រការ១៦_**

ក្នុងករណីចាំបាច់ ក្រសួងបរិស្ថាននឹងធ្វើការកែសំរួល ឬ កែប្រែលើគោលការណ៍ណែនាំទូទៅនេះ ដោយក្រសួងជូនដំណឹងក្នុងរយៈពេលបីខែជាមុន។

គោលការណ៍ណែនាំស្តីពីការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ តាមផ្នែកនិមួយៗ នឹងត្រូវរៀបចំដោយនាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលនឹងដាក់ឱ្យប្រើជាផ្លូវការដោយប្រកាសរបស់ក្រសួងបរិស្ថាន។

**ប្រការ១៧_**

បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៨_**

អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ខុទ្ទកាល័យ នាយកដ្ឋានអង្កេត ពិនិត្យការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានរាជធានី-ខេត្ត ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

មុំក_ម៉ារ៉េត

បណ្ឌិត.ជីវវិទូ

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់ក្រសួង/ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលារាជធានី/ខេត្ត "ដើម្បីជូនជ្រាប"
- ដូចប្រការ ១៨ "ដើម្បីអនុវត្ត"
- ឯកសារ/កាលប្បវត្តិ

**កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថានសំរាប់គំរោងស្នើសុំដែលអនុម័តដោយស្ថាប័នអនុម័តគំរោង/ក.អ.ក ឬ អនុគណៈកម្មការវិនិយោគរាជធានី-ខេត្ត**




**កំណត់សំគាល់**

វ.ហ.ប.ដ : ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង
វ.ហ.ប : ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ
ក.អ.ក : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ក្រ.ប : ក្រសួងបរិស្ថាន
អ.គ.វ.រ.ខ : អនុគណៈកម្មការវិនិយោគរាជធានី-ខេត្ត
ម.ប.រ.ខ : មន្ទីរបរិស្ថានរាជធានី-ខេត្ត

ម.គ : ម្ចាស់គំរោង
ផ.គ.ប : ផែនការគ្រប់គ្រងបរិស្ថាន
ព.ប.ប : ពាក្យសុំពិនិត្យបញ្ហាបរិស្ថាន

## ឧបសម្ព័ន្ធទី១ : ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

### ១. គោលបំណង

គោលបំណងនៃការរៀបចំគោលការណ៍ណែនាំទូទៅនេះ គឺណែនាំដល់ភាគីពាក់ព័ន្ធដូចជា អ្នកពិនិត្យរបាយការណ៍ ម្ចាស់គំរោង ក្រុមហ៊ុនទីប្រឹក្សា អ្នកសំរេចចិត្ត/អ្នកអនុម័តគំរោង និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ដើម្បីអនុវត្តតាមគោលការណ៍ណែនាំ។

### ២. និយមន័យ

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង (វ.ហ.ប.ដ) :** គឺជាការសិក្សាដំបូងលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនគឺពឹងផ្អែកទៅលើទិន្នន័យមានស្រាប់ដែលមាននៅក្នុងនិងជុំវិញតំបន់គំរោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គំរោង សំដៅរកវិធានការកាត់បន្ថយនូវហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កំរិតអតិបរមា។
ប្រសិនបើ ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូងបញ្ជាក់ថា មានការប៉ះពាល់ដល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរ នោះទាមទារឱ្យម្ចាស់គំរោងត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

**ការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ (វ.ហ.ប) :** គឺជាការសិក្សាលំអិតលើធនធានបរិស្ថានរូបសាស្ត្រ បរិស្ថានជីវសាស្ត្រ និងធនធានសេដ្ឋកិច្ច-សង្គម ហើយភាគច្រើនគឺពឹងផ្អែកទៅលើទិន្នន័យចំបង ដែលមាននៅក្នុងនិងជុំវិញតំបន់គំរោង ដើម្បីជាមូលដ្ឋានក្នុងការកំណត់ ព្យាករ និងវិភាគនូវសក្តានុពលនៃហេតុប៉ះពាល់បរិស្ថាន និងសង្គមធ្ងន់ធ្ងរដែលអាចកើតមានឡើងដោយសារសកម្មភាពរបស់គំរោង សំដៅរកវិធានការកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានឱ្យដល់កំរិតអប្បបរមា និងបង្កើនហេតុប៉ះពាល់វិជ្ជមានឱ្យដល់កំរិតអតិបរមា។

**ផែនការគ្រប់គ្រងបរិស្ថាន :** គឺជាកម្មវិធីត្រួតពិនិត្យបរិស្ថានដូចមាននៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬ ពេញលេញ ដែលបានរៀបចំឡើងដោយម្ចាស់គំរោង និងមានការឯកភាពពីក្រសួងបរិស្ថាន។

**ការចូលរួមពីសាធារណៈជន :** គឺជាការចូលរួមពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធ ទៅនឹងគំរោងអភិវឌ្ឍន៍ដែលអ្នកពាក់ព័ន្ធទាំងនោះរួមមាន : ក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធ ម្ចាស់ក្រុមហ៊ុន ក្រុមហ៊ុនទីប្រឹក្សា តំណាងប្រជាពលរដ្ឋដែលរងនូវការប៉ះពាល់ និងតំណាងអង្គការក្រៅរដ្ឋាភិបាលដែលមានការពាក់ព័ន្ធទៅនឹងតំបន់គំរោង។

លក្ខណៈវិនិច្ឆ័យសំរាប់ការវាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង គឺ ៖

- ប្រព័ន្ធទិន្នន័យដែលទទួលបានទាំងអស់មិនទាន់គ្រប់ជ្រុងជ្រោយ ភាគច្រើនជាទិន្នន័យដែលមានស្រាប់ ( ទិន្នន័យបន្ទាប់បន្សំ ) ។

- ការវាយតំលៃទៅលើហេតុប៉ះពាល់បរិស្ថានដំបូងក៏អាចមិនសុក្រឹត្យផងដែរ គឺគ្រាន់តែលក្ខណៈទទួលយកបានតែប៉ុណ្ណោះ ។

- ការទទួលស្គាល់នូវរបាយការណ៍ **វ.ហ.ប.ដ** សំរាប់ការវិនិយោគ គឺសំដៅលើកទឹកចិត្តដល់វិនិយោគិនដែលគោរព និងអនុវត្តតាមច្បាប់ជាធរមាន ដោយធ្វើការវិនិយោគទាន់ពេលវេលា ។

## ៣. ខ្លឹមសារនៃគោលការណ៍ណែនាំទូទៅ

### សេចក្តីសង្ខេប

នៅក្នុងផ្នែកនេះ ត្រូវសង្ខេបនូវខ្លឹមសារសំខាន់ៗនៃរបាយការណ៍ទាំងមូល ដូចជាគោលបំណង សកម្មភាពគំរោង ធនធានបរិស្ថានដែលមានស្រាប់ លទ្ធផលនៃការចូលរួមរបស់សាធារណៈជន ការកំណត់ហេតុប៉ះពាល់បរិស្ថាន និងសង្គម ព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយ ផែនការគ្រប់គ្រងបរិស្ថាន សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថាន ។

### ជំពូកទី១. សេចក្តីផ្តើម

- លក្ខណៈទូទៅនៃគំរោង ៖ ត្រូវរៀបចំសង្ខេបពីប្រវត្តិ និងមូលហេតុដែលគំរោងត្រូវបានបង្កើតឡើង ព្រមទាំងស្ថានភាពទូទៅនៃតំបន់គំរោង ។
- គោលបំណងនៃការរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។
- វិធីសាស្ត្រ និងទំហំនៃការសិក្សា ៖ ត្រង់ចំណុចនេះត្រូវរៀបរាប់អំពីតំរូវការព័ត៌មាន-ទិន្នន័យ វិធីសាស្ត្រប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ។ ក្នុងករណីការរៀបចំរបាយការណ៍ **វ.ហ.ប** ម្ចាស់គំរោងត្រូវសិក្សាល់អិតនូវវិធីសាស្ត្រ និងរៀបចំជំពូកថ្មីមួយដាច់ដោយឡែក ។

### ជំពូកទី២. ក្របខំណ្ឌច្បាប់

ក្នុងក្របខ័ណ្ឌច្បាប់ ម្ចាស់គំរោងត្រូវពិពណ៌នាអំពីច្បាប់ អនុក្រឹត្យ និងគោលនយោបាយនានាដែលមានការពាក់ព័ន្ធទៅនឹងប្រភេទគំរោងដែលនឹងត្រូវបានអនុវត្ត ។ រាល់ខ្លឹមសារមាត្រានៃច្បាប់ និងបទបញ្ញត្តិ ដូចបានរៀបរាប់ខាងលើ ត្រូវតែមានការពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងគំរោងអភិវឌ្ឍន៍ ។

បទបញ្ញត្តិ និងស្តង់ដាបរិស្ថាន ដែលត្រូវយកមកអនុវត្តក្នុងគំរោង ត្រូវតែមានឯកសារយោងត្រឹមត្រូវ ឲ្យបានច្បាស់លាស់

## ជំពូកទី៣. ការពិពណ៌នាអំពីគំរោង

នៅក្នុងជំពូកនេះត្រូវរៀបរាប់ឱ្យបានលំអិត ដូចមានចែងនៅក្នុងរបាយការណ៍បុរេសិក្សាសមិទ្ធិលទ្ធភាព ឬរបាយការណ៍សិក្សាសមិទ្ធិលទ្ធភាព ឬផែនការមេរបស់ក្រុមហ៊ុន ដែលមានចំណុចមួយចំនួនដូចខាងក្រោម :

- ប្រវត្តិ និងបទពិសោធន៍របស់ក្រុមហ៊ុន/គំរោង
- ទីតាំងគំរោង (ត្រូវភ្ជាប់មកជាមួយនូវផែនទីរដ្ឋបាលតំបន់ និងទីតាំងគំរោង)
- ប្រភេទ/ទំហំគំរោង និងពេលវេលានៃសកម្មភាពគំរោង (ដំណាក់កាលមុនប្រតិបត្តិគំរោង ប្រតិបត្តិ និងបញ្ចប់គំរោង)
- ផែនការសកម្មភាពការងារ ឧទាហរណ៍ : (១)-ប្រភព និងបរិមាណវត្ថុធាតុដើមដែលត្រូវប្រើប្រាស់ (២)-តំរូវការគ្រឿងចក្រ (៣)-តំរូវការកំលាំងពលកម្មក្នុងស្រុក និងក្រៅប្រទេស (៤)-បរិមាណផលិតផលសំរេច (៥)-ចំណូល-ចំណាយ (៦)-ខ្សែសង្វាក់ផលិតកម្ម (៧)-ផែនការគ្រប់គ្រងសំណល់គ្រប់ប្រភេទ។ល។
- កម្មវិធីសកម្មភាពការងាររបស់គំរោង។

## ជំពូកទី៤. ការពិពណ៌នាពីធនធានបរិស្ថានដែលមានស្រាប់

ជំពូកនេះត្រូវពិពណ៌នាអំពីធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម (ទិន្នន័យដែលបានសិក្សាកន្លងមក និងទិន្នន័យថ្មី) នៅក្នុងនិងជុំវិញតំបន់គំរោង រួមមាន :

### ៤.១ បរិស្ថានធម្មជាតិ

### ៤.១.១ ធនធានរូបសាស្ត្រ

- ដី : ភូគព្ភសាស្ត្រ សណ្ឋានដី/ជំរាលលេខា ចំណាត់ថ្នាក់ប្រភេទដី ការហូរច្រោះ និងកំណកដី។ ក្នុងករណីរៀបចំ វ.ហ.ប ត្រូវសិក្សាលំអិតបន្ថែមពីការរញ្ជួយដី ភូគព្ភសាស្ត្រ (ធនធានរ៉ែ បើសិនជាមាន)
- អាកាសធាតុ : សីតុណ្ហភាព របបទឹកភ្លៀង របបនិងល្បឿនខ្យល់ សំពាធខ្យល់ ទិសខ្យល់ និងសំណើម
- គុណភាពខ្យល់ (ការវិភាគគុណភាពខ្យល់ក្នុងតំបន់គំរោង) សំលេង និងរំញ័រ (ការវាស់សំលេង និងរំញ័រក្នុងតំបន់គំរោង)
- ជលសាស្ត្រ : បរិមាណ និងគុណភាពទឹកលើដី-ក្រោមដី (ការវិភាគគុណភាពទឹកក្នុងតំបន់គំរោង) ធារទឹក ចរន្តទឹក។

### ៤.១.២ ធនធានជីវសាស្ត្រ

- ព្រៃឈើ : ផ្ទៃដីព្រៃឈើ ប្រភេទគំរបព្រៃឈើ និងចំណាត់ថ្នាក់ប្រភេទឈើ
- ប្រភេទសត្វព្រៃ ប្រភេទសត្វកម្រ ប្រភេទជិតផុតពូជ និងការបំលាស់ទី
- ទីជំរក
- ជីវៈចម្រុះ និងជីវសាស្ត្រព្រមទាំងប្រព័ន្ធអេកូឡូស៊ី
- ប្រព័ន្ធដីសើម (ភ្ជាប់មកជាមួយនូវផែនទីពាក់ព័ន្ធ)

## ៤.២ ធនធានសេដ្ឋកិច្ច-សង្គម

- ប្រជាសាស្ត្រ និងការតាំងទីលំនៅ
- ស្ថានភាពសេដ្ឋកិច្ច : មុខរបរ ប្រាក់ចំណូល ( ប្រភពចំណូលសំខាន់ និងបន្ទាប់បន្សំ)
- ការប្រើប្រាស់ដី
- ការប្រើប្រាស់ទឹក
- ការប្រើប្រាស់ថាមពល
- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ
- ការអប់រំ
- សុខភាព និងសុខមាលភាពសាធារណៈ
- សម្បត្តិវប្បធម៌ សំណង់ប្រវត្តិសាស្ត្រ ប្រាសាទបុរាណ វត្តអារាម/ទំនៀមទំលាប់ ប្រពៃណី ជនជាតិដើម ឬជនជាតិភាគតិច
- តំបន់ទេសចរណ៍ ។

## ជំពូកទី៥. ការចូលរួមពីសាធារណៈជន

ក្នុងជំពូកនេះ ត្រូវពិពណ៌នាលំអិតពីលទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ លើចំណុចមួយចំនួនដូចខាងក្រោម :

៥.១ សេចក្តីផ្តើម

៥.២ ការចូលរួមរបស់សាធារណៈជន

- ការផ្សព្វផ្សាយដល់អាជ្ញាធរ និងសហគមន៍មូលដ្ឋានពីគំរោងអភិវឌ្ឍន៍របស់ម្ចាស់គំរោង
- ការផ្តល់យោបល់របស់ក្រសួង/ស្ថាប័ន/អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន
- ការផ្តល់យោបល់របស់តំណាងអង្គការពាក់ព័ន្ធ
- ការស្ទង់មតិជាមួយប្រជាជនមូលដ្ឋានដែលរងនូវការប៉ះពាល់

៥.៣ សន្និដ្ឋានរួមលើលទ្ធផលពិគ្រោះយោបល់ ។

## ជំពូកទី៦. ហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

ក្នុងជំពូកនេះ ត្រូវពិពណ៌នាពីហេតុប៉ះពាល់បរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិជ្ជមានសំខាន់ៗដែលអាចកើតឡើងពីសកម្មភាពគំរោងដូចជា :

៦.១ ពិពណ៌នាពីហេតុប៉ះពាល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន នៅក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង ( មុនសាងសង់ និងសាងសង់) ប្រតិបត្តិ និងបញ្ចប់គំរោង ព្រមទាំងលើកឡើងនូវវិធានការកាត់បន្ថយ ។

៦.២ សង្ខេបចំណុច ៦.១ ស្តីពីទំហំនៃហេតុប៉ះពាល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមអវិជ្ជមាន និងវិធានការកាត់បន្ថយ នៅក្នុងតារាងសង្ខេបដូចមានគំរូបង្ហាញនៅក្នុងឧបសម្ព័ន្ធទី២។

៦.៣ ក្នុងករណីរៀបចំ វ.ហ.ប ត្រូវសិក្សាលំអិតបន្ថែមពីបណ្តុំនៃហេតុប៉ះពាល់។

៦.៤ ពិពណ៌នាពីហេតុប៉ះពាល់ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គមវិជ្ជមាន។

## ជំពូកទី៧. ផែនការគ្រប់គ្រងបរិស្ថាន

នៅក្នុងផ្នែកនេះ ម្ចាស់គំរោងចាំបាច់ត្រូវមានមូលនិធិគ្រប់គ្រាន់សំរាប់កិច្ចការពារបរិស្ថាន និងបង្កើតផ្នែក/ក្រុមមួយដែលមានបុគ្គលិកជំនាញប្រកបដោយសមត្ថភាព ឧបករណ៍ វិធីសាស្ត្រ និងកាលវិភាគត្រឹមត្រូវសំរាប់ត្រួតពិនិត្យគុណភាពបរិស្ថាន ដោយសហការឱ្យបានជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដើម្បីកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានរបស់គំរោងទៅលើធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម។

ផែនការគ្រប់គ្រងបរិស្ថាននេះ រួមមាន:

៧.១ ការសង្ខេបពីហេតុប៉ះពាល់អវិជ្ជមានសំខាន់ៗ និងវិធានការកាត់បន្ថយ

៧.២ កម្មវិធីបណ្តុះបណ្តាល

៧.៣ កម្មវិធីត្រួតពិនិត្យបរិស្ថាន ក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិគំរោង និងបញ្ចប់គំរោង ដែលក្នុងនោះម្ចាស់គំរោងត្រូវបញ្ជាក់ពី :

- ស្ថាប័នត្រួតពិនិត្យសំរាប់ការអង្កេតតាមដានគំរោង
- កំណត់នូវប៉ារ៉ាម៉ែត្រដែលត្រូវត្រួតពិនិត្យ
- វិធីសាស្ត្រក្នុងការត្រួតពិនិត្យ
- បទដ្ឋានបរិស្ថាន ឬ គោលការណ៍ណែនាំណាមួយដែលត្រូវយកមកអនុវត្តក្នុងការត្រួតពិនិត្យ
- កម្មវិធី និងខួបដែលត្រូវត្រួតពិនិត្យ
- ការវាយតំលៃទៅលើលទ្ធផលនៃការត្រួតពិនិត្យដោយម្ចាស់គំរោងផ្ទាល់
- ការរៀបចំរបាយការណ៍ប្រចាំត្រីមាស ដើម្បីផ្ញើជូនក្រសួងបរិស្ថាន និងក្រសួង/ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៨. ការវិភាគសេដ្ឋកិច្ច និងតំលៃបរិស្ថាន

ក្នុងករណី រៀបចំ វ.ហ.ប ម្ចាស់គំរោងត្រូវពិពណ៌នាអំពីផលចំណេញដែលទទួលបានពីគំរោង ដោយប្រៀបធៀបទៅនឹងតំលៃ និងទំហំនៃការខូចខាតបរិស្ថានដែលកើតមានឡើងពីសកម្មភាពគំរោង។

## ជំពូកទី៩. សន្និដ្ឋាន និងអនុសាសន៍

ការសន្និដ្ឋាននៃការសិក្សារបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន គឺត្រូវបង្ហាញពីការកាត់បន្ថយឱ្យបាននូវហេតុប៉ះពាល់អវិជ្ជមាន លើធនធានរូបសាស្ត្រ ជីវសាស្ត្រ និងសេដ្ឋកិច្ច-សង្គម។ ក្នុងសេចក្តីសន្និដ្ឋាននេះ ក្រុមហ៊ុន និងក្រុមហ៊ុន

ទីប្រឹក្សាចាំបាច់បំផុតត្រូវបង្ហាញអោយឃើញការវិនិយោគ ដោយលើកឡើងនូវវិធានការកាត់បន្ថយហេតុប៉ះពាល់បរិស្ថានអវិជ្ជមានទាំងនេះ បង្ហាញបាននូវនិរន្តរភាពជាវិជ្ជមាននៃបរិស្ថាន និងការលើកកំពស់ជីវភាពរបស់សហគមន៍ដែលពាក់ព័ន្ធនៅពេលមានការអភិវឌ្ឍន៍គំរោងកើតមានឡើងក្នុងតំបន់គំរោង។

ក្នុងផ្នែកនេះ ម្ចាស់គំរោង និងក្រុមហ៊ុនទីប្រឹក្សាធានាអះអាង និងទទួលខុសត្រូវលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រមទាំងលើកឡើងនូវអនុសាសន៍ដែលពាក់ព័ន្ធនឹងគំរោង។

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

ឧបសម្ព័ន្ធទី២ : តារាងសង្ខេបសំរាប់កំណត់ទំហំនៃហេតុប៉ះពាល់បរិស្ថាន និងវិធានការកាត់បន្ថយ

| ធនធានបរិស្ថានធម្មជាតិ និងសេដ្ឋកិច្ច-សង្គម | ហេតុប៉ះពាល់ អវិជ្ជមាន | កំណត់ទំហំនៃហេតុប៉ះពាល់ | | | វិធានការកាត់បន្ថយ | សំគាល់ |
|---|---|---|---|---|---|---|
| | | តិចតួច | មធ្យម | ខ្លាំង | | |
| ១. ហេតុប៉ះពាល់ក្នុងដំណាក់កាលមុនប្រតិបត្តិគំរោង | | | | | | |
| ១.១ ដំណាក់កាលមុនសាងសង់ | | | | | | |
| ក. ធនធានបរិស្ថានធម្មជាតិ | | | | | | |
| - ធនធានរូបសាស្ត្រ | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |
| ១.២ ដំណាក់កាលសាងសង់ | | | | | | |
| ក. ធនធានបរិស្ថានធម្មជាតិ | | | | | | |
| - ធនធានរូបសាស្ត្រ | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |
| ២. ហេតុប៉ះពាល់ក្នុងដំណាក់កាលប្រតិបត្តិគំរោង | | | | | | |
| ក. ធនធានបរិស្ថានធម្មជាតិ | | | | | | |
| - ធនធានរូបសាស្ត្រ | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |
| ៣. ហេតុប៉ះពាល់ក្នុងដំណាក់បញ្ចប់គំរោង | | | | | | |
| ក. ធនធានបរិស្ថានធម្មជាតិ | | | | | | |
| - ធនធានរូបសាស្ត្រ | | | | | | |
| - ធនធានជីវសាស្ត្រ | | | | | | |
| ខ. ធនធានសេដ្ឋកិច្ច-សង្គម | | | | | | |